ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

លេខ ១៦៣១ ព.ណ អភទ

ភ្នំពេញ, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជូនដំណឹងដល់ លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាប្រធាន សមាគម ក្រុមហ៊ុន និងសហគ្រាសឯកជនក្នុងស្រុកទាំងអស់ជ្រាបថា៖ ក្នុងគោលបំណងជំរុញការនាំចេញផលិតផលខ្មែរ និងស្វែងរកទីផ្សារនៅក្រៅប្រទេស ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ ក្រុមហ៊ុន **CHINA IMPORT-FOOD MALL CO., LTD. (CIFM)** របស់ប្រទេសចិន ដើម្បីបញ្ជូនផលិតផលខ្មែរទៅ ទីផ្សារចិនតាមរយៈផ្សារទំនើបរបស់ក្រុមហ៊ុននេះ។ ក្រុមហ៊ុនខាងលើបានផ្តល់ទីតាំងក្នុងផ្សារទំនើបរបស់ខ្លួនដល់ភាគីកម្ពុជា សម្រាប់រៀបចំ **ពន្លាជាតិកម្ពុជា (CAMBODIA PAVILION)** នៅទីក្រុងហៃនីង (**Haining**) ខេត្តស៊ីជាំង (**Zhejiang**) សាធារណរដ្ឋប្រជាមានិតចិន ដើម្បីដាក់តាំងបង្ហាញ ផ្សព្វផ្សាយ និង លក់ផលិតផលខ្មែរនៅទីនោះ។

អាស្រ័យហេតុនេះ សូម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាប្រធាន សមាគម ក្រុមហ៊ុន និងសហគ្រាសឯកជនក្នុងស្រុកទាំងអស់ដែលមានបំណងចង់បញ្ជូនផលិតផលរបស់ខ្លួនទៅទីផ្សារចិន អញ្ជើញមកដាក់ ពាក្យសុំចុះឈ្មោះចូលរួម នៅនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ នៃក្រសួងពាណិជ្ជកម្ម។ ***កាលបរិច្ឆេទទទួលពាក្យ និងទទួលគំរូ ផលិតផល គឺចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៦ (សម្រាប់ការទទួលពាក្យ) និងរហូតដល់ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ (សម្រាប់ការទទួលគំរូផលិតផល)។***

ព័ត៌មានបន្ថែម សូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំងនៅជាន់ទី២ នៃអគារទីស្តីការក្រសួងពាណិជ្ជកម្ម ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឬ ក្រុមហ៊ុនបេសឡាយហ៍ប្រជាក់ ដែលមានទីស្នាក់ការកណ្តាល លេខ២៦ ផ្លូវ២៨១ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

*ទំនាក់ទំនង:*

- *នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ* Tel: 016 828 574 / 086 333 933
  E-mail : vuthyna.monine@gmail.com
- *ក្រុមហ៊ុនបេសឡាយហ៍ប្រជាក់* Tel: 023 884 088 / 012 793 222
  E-mail : meavsoktry@yahoo.com
  WeChat: soktry9696

សូមអរគុណ!